00379056

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 09 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/54

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរ
## នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"
## សាធារណៈ:

**សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ**

**ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩ -ថ្ងៃជំនុំជម្រះទី ៤៩**

រៀបចំដោយ: ឌុច ផារី និង Natacha WEXELS-RISER

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Crippa MATTEO,លោកស្រី សែ កុលវុឌ្ឍី,កញ្ញា Natacha Wexels-Riser, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖លោក Anees Ahmed , លោក តាន់ សេណារ៉ុង, លោក Zachery Lampell, លោក Christopher Hale លោក កេង សុម៉ារិទ្ធិ លោក Pak Chanlino |

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

| |
|---|
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux, លោកស្រី Heleyn Unac,លោក ចាន់ រ៉ាវុធ, កញ្ញា Lucile NATTIEZ, លោក Alexandre Prezanti |
| មេធាវីដំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖កញ្ញា Silke Studzinsky, កញ្ញា ទី ស្រីនណា, លោក Alain Werner, កញ្ញា ម៉ុច សុវណ្ណារី,លោក គីម ម៉េងឃី, លោក គង់ ពិសី |
| មេធាវីការពារសាក្សី៖ លោក គង់ សំអ៊ុន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក កួវ កែវរតនៈ(វត្តមាន) លោក សាន រាដា (វត្តមាន) លោក អ៊ុច អារុណ |
| ផ្សេងៗ៖ |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ | ចាប់ផ្ដើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.២០ |
| សម្រាកព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាក | ចាប់ផ្ដើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកល្ងាច | ចាប់ផ្ដើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៥ ម៉ោង ១០ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សួរសំនួរដល់សាក្សី គក ស្រស់ ទាក់ទង និងអង្គហេតុប្រតិបត្តិការ ស ២១ រួមទាំង ជើងឯក | អង្គជំនុំជម្រះ | ៩.០៨ | ១០.២៩ |
| សេចក្ដីសម្រេច និងសេចក្ដីណែនាំទាក់ទង នឹងការសួរសំណួរដល់ជនជាប់ចោទ ក្នុង អំឡុងពេលធ្វើសក្ខីកម្មរបស់សាក្សី និង សេចក្ដីសម្រេចទាក់ទងនិងសំណើរបស់ | អង្គជំនុំជម្រះ | ១០.៥០ | ១០.៥៩ |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. / C.E.T.C.

| | | | |
|---|---|---|---|
| មេធាវីការពារក្តីដែលស្នើសុំពេលវេលាបន្ថែមក្នុងការសួរសំនួរដល់សាក្សី | | | |
| សួរសំនួរដល់សាក្សី គក ស្រស់ ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១ រួមទាំងជើងឯក | សហព្រះរាជអាជ្ញា | ១១.០០ | ១១.១៤ |
| សួរសំនួរដល់សាក្សី គក ស្រស់ ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១ រួមទាំងជើងឯក | មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ | ១១.១៥ | ១១.៣៦ |
| សួរសំនួរដល់សាក្សី គក ស្រស់ ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១ រួមទាំងជើងឯក | មេធាវីការពារក្តី | ១១.៣៦ | ១១.៤២ |
| សេចក្តីសង្កេតរបស់ជនជាប់ចោទ ទាក់ទងនឹងសក្ខីកម្មរបស់សាក្សី គក ស្រស់ និងសំនួរសួរទៅកាន់ជនជាប់ចោទ | អង្គជំនុំជម្រះ | ១១.៤៣ | ១១.៥៧ |
| សួរសំនួរដល់សាក្សី សួស ធី ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១ រួមទាំងជើងឯក | អង្គជំនុំជម្រះ | ១៣.៣៤ | ១៦.២០ |
| | | | |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**ការសួរសំនួរដល់សាក្សី គក ស្រស់ ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១**

- អង្គជំនុំជម្រះបន្តតាំងសំនួរដល់សាក្សី គក ស្រស់ ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១ ។

**សេចក្តីសម្រេច និង សេចក្តីណាំនាំទាក់ទងនឹងការសួរសំណួរដល់ជនជាប់ចោទក្នុងអំឡុងពេលធ្វើសក្ខីកម្មរបស់សាក្សី និង សេចក្តីសម្រេចទាក់ទងនិងសំណើរបស់មេធាវីការពារក្តី**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE

**ដែលស្នើសុំពេលវេលាបន្ថែមក្នុងការសួរសំនួរដល់សាក្សី**

- អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចទាក់ទងនឹងការសួរសំណួរដល់ជនជាប់ចោទ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី និងចេញនូវសេចក្តីសម្រេចទាក់ទងនឹងសំណើរបស់មេធាវីការពារក្តី ដែលបានស្នើសុំពេលវេលាបន្ថែមសម្រាប់សួរសំនួរដល់សាក្សី (សូមមើលសេចក្តីសម្រេចខាងក្រោម)។

**ភាគីតាំងសំនួរដល់សាក្សី គក ស្រស់**

- សហព្រះរាជអាជ្ញា មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ (ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀត) មេធាវីការពារក្តី តាំងសំនួរដល់សាក្សី គក ស្រស់ ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១ ។

**សេចក្តីសង្ខេបរបស់ជនជាប់ចោទទាក់ទងនឹងសក្ខីកម្មរបស់សាក្សី គក ស្រស់ និងសំនួររបស់អង្គជំនុំជម្រះដល់ជនជាប់ចោទ**

- ជនជាប់ចោទមានការសង្ស័យថាតើសាក្សី គក ស្រស់ ពិតជាបានបំពេញការងារជាសន្តិសុខនៅ ស ២១ មែនដែរឬទេ ។

**អង្គជំនុំជម្រះតាំងសំនួរដល់សាក្សី សួស ធី ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១**

- អង្គជំនុំជម្រះ តាំងសំនួរដល់សាក្សី សួស ធី ទាក់ទងនិងអង្គហេតុប្រតិបត្តិការ ស ២១ ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោងរបស់អជសដ | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត, សម្ងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | | | |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

| | | | | |
|---|---|---|---|---|
| E3/427 | D91/I-Annex 4.6 | សៀវភៅដែលមានចំណងជើងថា "សំឡេងពីមន្ទីរ ស ២១ ភាពព្រឺខ្លាចនិងប្រវត្តក្នុងគុកសម្ងាត់របស់ ប៉ុល ពត" ដែលនិពន្ធដោយលោក David Chandler | សាធារណៈ | 00191816-00192089; 00192667-00192932, ជាពិសេសត្រង់ទំព័រ 00192712, 00192716, 00192775, 00192821, 00192832, 00192845; 00357247-00357451 |
| E3/428 | D78/10 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គគ ស្រស់ របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៨ | សាធារណៈ: កោសលុប | 00195395-00195401, 00186795-00186801, 00191045-00191051. លុបពត៌មានទាក់ទងនិងបុគ្គល |
| E3/245 | D48/2-Annex 1 | ឧបសម្ព័ន្ធ ១៖ កំណត់ហេតុនៃការចុះស៊ើបអង្កេតដល់ទីកន្លែងកើតហេតុនៅទួលស្លែង ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ "រូបថតមន្ទីរ ស ២១ និង វិន័យសន្តិបាល" | សម្ងាត់ | 00198028-00198081, 00181395-00181448, ជាពិសេសត្រង់ទំព័រ 00181448 (KH), 00198081 (ENG). មាននៅក្នុង E3 folder រួចហើយ |
| E3/16 | D45/1/8 | រូបភាពថតពីលើអាកាសដែលបង្ហាញពីបរិវេណនៅជិតមន្ទីរ ស ២១ | សាធារណៈ: | 00189137-00189137. មាននៅក្នុង E3 folder រួចហើយ |
| E3/250 | D69- An A-P0143 | រូបភាពអ្នកទោសឈ្មោះ វ៉ាន់ ណាត ជាប់នៅ ស ២១ បន្ទប់ឃុំឃាំងមនុស្ស | សាធារណៈ: | P 00000026-00000026. មាននៅក្នុង E3 folder រួចហើយ |
| E3/249 | D69-An A-P0143 | រូបភាពរបស់អ្នកទោស ស ២១ គូរដោយ វ៉ាន់ ណាត ដែលពិពត៌នាអំពីអ្នកទោសដែលត្រូវបានដាក់ឲ្យដេកជាជួរ | សាធារណៈ: | P 00000027-00000027. មាននៅក្នុង E3 folder រួចហើយ |
| E3/429 | D59, Annex 15 | ឧបសម្ព័ន្ធ ១៥៖ កំណត់ហេតុនៃការ | សាធារណៈ: | 00164577-00164582, ជាពិសេសត្រង់ទំព័រ |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

00379061



| | | | | |
|---|---|---|---|---|
| | | សម្ភាសរបស់ គក ស្រស់ ជាមួយ លោក David Chandler | កោសលុប | 00164564 និង 00164580; 00338085-00338094; 00280347-00280353. លុបនូវចម្លើយតបរបស់សាក្សី ទៅនិងសំណួរ "តើអ្នកអាយុប៉ុន្មាន និង តើអ្នកមកពីណា?" នៅត្រង់ទំព័រទីមួយ |
| E/430 | D59, Annex 16 | ឧបសម្ព័ន្ធ ១៦៖ កំណត់ហេតុនៃការសម្ភាសរបស់ គក ស្រស់ ជាមួយ លោក Doug NIven | | 00164562-00164576, ជាពិសេសត្រង់ទំព័រ 00164572; 00241947-00241971, 00280354-00280368 |
| E3/431 | IS 6.1 | សារាចររបស់មន្ទីរ ស ២១ ទាក់ទង និងវិន័យការពារខ្មាំង | សាធារណៈ | 00008086-00008114, ជាពិសេសត្រង់ទំព័រ 00008091 |
| | | | | |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- **សេចក្ដីណែនាំទាក់ទងនឹងការសួរសំណួរដល់ជនជាប់ចោទ ក្នុងអំឡុងពេលធ្វើសក្ខីកម្មសាក្សី**

នៅថ្ងៃទី ២២ ខែ កក្កដា សហព្រះរាជអាជ្ញាបានលើកឡើងនូវបញ្ហាទាក់ទងនឹងការសួរសំណួរដល់ជនជាប់ចោទក្នុងអំឡុងពេលធ្វើសក្ខីកម្មសាក្សី ដោយកត់សម្គាល់ថា ការអនុវត្តបែបនេះ អាចជាការបំភ័យដល់សាក្សី ។

ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ៣ ក៏បានស្នើសុំផងដែរថា ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីក្រុមណាមួយមានបំណងចោទសួរដល់ជនជាប់ចោទ ក្នុងអំឡុងពេលធ្វើសក្ខីកម្មសាក្សី នោះគប្បីផ្ដល់ពេលវេលាបន្ថែមសម្រាប់គោលបំណងនេះ។

ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះសូមធ្វើការណែនាំដល់ភាគីទាំងអស់ឲ្យបានជ្រាបថា៖



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C. C.E.T.C.

១. មិនមានការហាមឃាត់ភាគីក្នុងការសួរសំណួរដល់ជនជាប់ចោទ ក្នុងដំណាក់កាលដែលពាក់ព័ន្ធ ក្នុងពេលធ្វើសក្ខីកម្មសាក្សីនោះទេ ។ អង្គជំនុំជម្រះនឹងសម្រេច អំពីការអនុញ្ញាត ឬមិនអនុញ្ញាតនូវការសួរសំណួររបៀបនេះ អាស្រ័យទៅតាមករណីជាក់ស្តែងនីមួយៗ ។

២. ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អាចប្រើប្រាស់ពេលវេលា ដែលបានប្រគល់ឱ្យសម្រាប់សួរសំណួរដល់សាក្សី សួរសំណួរដែលពាក់ព័ន្ធ ដល់ជនជាប់ចោទបាន ។ ក៏ប៉ុន្តែ មិនមានការផ្តល់ពេលវេលាបន្ថែមសម្រាប់ការសួរសំណួរ ក្នុងករណីបែបនេះទេ ។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានស្នើសុំឱ្យសួរសំណួរដែលនៅសេសសល់ដល់សាក្សី ឬជនជាប់ចោទ ដែលមេធាវីមិនមានលទ្ធភាពសួរចប់ ក្នុងអំឡុងពេលដែលបានប្រគល់ឱ្យ ជូនទៅអង្គជំនុំជម្រះ ។

សហព្រះរាជអាជ្ញាបានគាំទ្រសំណើនេះ ប៉ុន្តែ បានកត់សម្គាល់ថា ប្រសិនបើអង្គជំនុំជម្រះប្រកាន់យកនូវការអនុវត្តបែបនេះ នោះសំណួរគួរតែត្រូវបានបែងចែកជាប្តូងដោយផ្ទាល់មាត់ ដើម្បីសន្សំពេលវេលាដែលតម្រូវឱ្យមានការបកប្រែជាលាយលក្ខអក្សរជាបីភាសារ ។

មេធាវីការពារជនជាប់ចោទបានជំទាស់ទៅនឹងសំណើនេះ ដោយលើកឡើងថា នេះគ្រាន់តែជាមធ្យោបាយសាមញ្ញមួយ ដើម្បីទទួលបានពេលវេលាបន្ថែមសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរប៉ុណ្ណោះ ។

**សេចក្តីសម្រេចៈ**

អង្គជំនុំជម្រះមានកាតព្វកិច្ច ធានាថា សវនាការត្រូវប្រព្រឹត្តទៅដោយ ទាំងយុត្តិធម៌ ទាំងឆាប់រហ័ស ។ មានតម្រូវការជាប្រចាំដើម្បីពិនិត្យឡើងវិញនូវពេលវេលាដែលបានប្រគល់ឱ្យភាគីសម្រាប់សួរសំណួរ ខណៈដែលត្រូវធានាថា មេធាវីការពារជនជាប់ចោទក៏ត្រូវមានពេលវេលាគ្រប់គ្រាន់ផងដែរ ។ អង្គជំនុំជម្រះនឹងមិនប្រកាន់យកនូវការអនុវត្ត ដែលជាការបន្ថែមពេលវេលា ដែលបានប្រគល់ឱ្យដល់

ភាគីសម្រាប់សួរសំណួរនោះទេ ពីព្រោះថា ការធ្វើដូច្នេះ អាចធ្វើឲ្យបាត់បង់ នូវតុល្យភាពពេលវេលា ដែលបានបែងចែកទៅឲ្យភាគី ដោយរួមទាំងមេធាវីការពារជនជាប់ចោទផងដែរ ។

- **សេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីការពារក្តី ដែលទាមទារឲ្យមានការកំណត់ថេរៈវេលាក្នុងការសួរសំណួរទៅសាក្សីក្នុងរយៈពេលមួយស្មើគ្នាទៅនឹងថេរៈវេលាសរុបនៃថេរៈវេលាដែលអង្គជំនុំជម្រះបានផ្តល់អោយសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។**

អង្គជំនុំជម្រះបានទទួលនូវសំណើសុំរបស់សហមេធាវីការពារក្តីដែលបានស្នើសុំឲ្យមានការផ្តល់នូវថេរៈវេលានៃការចោទសួរដល់សាក្សីនីមួយៗក្នុងរយៈពេលមួយស្មើគ្នាទៅនឹងរយៈពេលសរុបដែលផ្តល់ជូនសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីការតាំងសំណួរដោយអង្គជំនុំជម្រះ។

ដោយហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យធ្វើការតាំងសំណួរក្នុងគោលបំណងគាំទ្រនូវការចោទប្រកាន់ អង្គជំនុំជម្រះយល់ឃើញថា ដើម្បីធានាដល់ការគោរពសិទ្ធិក្នុងការការពារខ្លួន និងជាពិសេសសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ដោយធ្វើយ៉ាងណាធានាឲ្យមានសមភាពនៃកម្លាំងនោះ វាអាចជាការចាំបាច់មួយដែលអង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យមានការបន្ថែមពេលវេលាដល់មេធាវីការពារដើម្បីធ្វើការចោទសួរលើសពីពេលវេលាដែលបានកំណត់ និងបានប្រកាសនៅក្នុងពេលសវនាការកន្លងមកទាក់ទងនឹងការបែងចែកពេលវេលាសម្រាប់ភាគី។

ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះត្រូវធានាថា ដំណើរការជំនុំជម្រះក្តីលើជនជាប់ចោទត្រូវប្រព្រឹត្តទៅក្នុងថេរៈវេលាមួយសមស្របដើម្បីឆ្លើយតបទៅនឹងកិច្ចដឹកនាំសវនាការឲ្យបានល្អ ដោយទីមួយ ភាគីត្រូវបានកំណត់រយៈពេលឲ្យធ្វើការតាំងសំណួរ និងទីពីរ សំណួរដែលមានលក្ខណៈច្រំដែល ឬមិនពាក់ព័ន្ធនឹងអង្គហេតុមិនត្រូវបានអនុញ្ញាតអោយសួរទេ។ ដោយផ្អែកលើទិដ្ឋភាពជាក់ស្តែង អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ឃើញថា មកទល់នឹងពេលនេះ មេធាវីការពារក្តីពុំដែលបានដាក់សំណើសុំឲ្យមានការបន្ថែមពេលវេលាណាមួយដល់ខ្លួន ដើម្បីធ្វើការចោទសួរនោះទេ ហើយខ្លួនក៏មិនដែលបានលើក



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E.C.C.C. C.E.T.C.

ឡើងពីបញ្ហាពាក់ព័ន្ធនឹងថេរៈវេលានេះដែរបន្ទាប់ពីការបញ្ចប់ការធ្វើសក្ខីកម្មសាក្សីណាម្នាក់។ ផ្ទុយទៅវិញមេធាវីការពារក្តីតែងតែបញ្ជាក់ថាខ្លួនគ្មានសំណួរអ្វីនឹងសួរទៅសាក្សីទៀតទេ ទោះបីជារយៈពេលដែលអនុញ្ញាតឱ្យធ្វើការតាំងសំណួរនោះមិនទាន់ត្រូវបានប្រើប្រាស់អស់ក៏ដោយ។

អង្គជំនុំជម្រះយល់ឃើញថា ដើម្បីអនុញ្ញាតឱ្យមានការរៀបចំកម្មវិធីសវនាការមួយប្រកបដោយយុត្តិធម៌ និងឆាប់រហ័សនោះ ថេរៈវេលាបច្ចុប្បន្នដែលបានផ្តល់ជូនដល់ភាគីរួចមកហើយនៅក្នុង សេចក្តីសម្រេចរបស់ខ្លួនគួរត្រូវបានរក្សាទុកនៅដដែល។ ប្រសិនជាមេធាវីការពារក្តីយល់ឃើញថា វាមានភាពចាំបាច់ចំពោះការសួរសំណួរដែលនៅសេសសល់ មេធាវីការពារក្តីអាចធ្វើការស្នើសុំមកអង្គ ជំនុំជម្រះដើម្បីសុំអនុញ្ញាតឱ្យមានការបន្ថែមពេលវេលាក្នុងការចោទសួរនូវសំណួរដែលមេធាវីយល់ ឃើញថាសមស្របនឹងធ្វើការចោទសួរដើម្បីធានាឱ្យមានការគោរពនូវសិទ្ធិរបស់ខ្លួននោះ អង្គជំនុំជម្រះនឹងធ្វើការសម្រេចតាមករណីជាក់ស្តែងនីមួយៗ។

**ហេតុដូច្នេះ**

អង្គជំនុំជម្រះសម្រេចរក្សាទុករយៈពេលនៃការតាំងសំណួរដូចដែលបានផ្តល់ជូនដល់មេធាវីការពារក្តីកន្លងមក។ អង្គជំនុំជម្រះធ្វើការបញ្ជាក់ផងដែរថាមេធាវីការពារក្តីមានសិទ្ធិស្នើសុំតាមករណីជាក់ស្តែងនីមួយៗ និងយោងទៅលើខ្លឹមសារនៃការសួរដេញដោល ឱ្យមានការបន្ថែមពេលវេលាក្នុងការចោទសួរសំណួរដែលមេធាវីការពារក្តីយល់ឃើញថាសមស្របដែលនឹងត្រូវចោទសួរដើម្បីធានាឱ្យមានការគោរពដល់សិទ្ធិរបស់ខ្លួន។

- បង្គាប់ឱ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃអង្គារ ទី២៨ ខែកក្កដា ឆ្នាំ២០០៩ ។

| ដីកាសម្រាប់ការលើកពេលសវនាការ |
| --- |
| • សវនាការនឹងបន្តទៅថ្ងៃអង្គារ ទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ ព្រឹក ។ NWR |

ភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារី Natacha WEXELS-RISER